ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ

កំណត់ហេតុកិច្ចប្រជុំថ្នាក់ដឹកនាំ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខែឧសភា ឆ្នាំ២០២៣

១. សេចក្តីផ្តើម

នៅថ្ងៃអង្គារ ៣រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៣ ចាប់ពីម៉ោង ០៣:០០នាទីរសៀល នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែឧសភា ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង ម៉ូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពី ឯកឧត្តមអនុប្រធានប្រចាំការ ឯកឧត្តម លោកជំទាវអនុប្រធាន ឯកឧត្តមទីប្រឹក្សា នាយកខុទ្ទកាល័យ ឯកឧត្តមអគ្គលេខាធិការ អគ្គលេខាធិការរង និងប្រធាននាយកដ្ឋានទាំងបួន។

កិច្ចប្រជុំដំណើរការទៅតាមរបៀបវារៈដូចខាងក្រោម ៖

១) មតិស្វាគមន៍ និងបើកកម្មវិធីរបស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង ម៉ូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

២) បទបង្ហាញរបាយការណ៍ថ្នាក់ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉ែត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ស្តីពីលទ្ធផលការងារប្រចាំខែឧសភា និងទិសដៅការងារខែមិថុនា ឆ្នាំ២០២៣។

៣) ការផ្តល់មតិយោបល់របស់ថ្នាក់ដឹកនាំ

៤) មតិសំណេះសំណាល បូកសរុបលទ្ធផល និងបិទកម្មវិធីដោយ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

២. ដំណើរការ និងមតិពិភាក្សានៃកិច្ចប្រជុំ

១) មតិស្វាគមន៍ និងបើកកិច្ចប្រជុំរបស់ ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ជាកិច្ចចាប់ផ្តើម ឯកឧត្តមទេសរដ្ឋមន្ត្រី បានបើកកិច្ចប្រជុំ និងមានមតិស្វាគមន៍ដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំប្រចាំខែ ដោយផ្ទាល់ និងតាមប្រព័ន្ធនិមិត្ត ដែលជាឱកាសមួយក្នុងការពិនិត្យលើការងាររបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ ឯកឧត្តមទេសរដ្ឋមន្ត្រីបានបញ្ជាក់ថា ការបើកកិច្ចប្រជុំ ការជួបជុំគ្នា ដើម្បីពិនិត្យអំពីវឌ្ឍនភាពការងារក្នុងខែកន្លងទៅ និងផែនការសកម្មភាពការងារដែលត្រូវធ្វើនាខែបន្ទាប់ ជាពិសេសការងារប្រជុំពេញអង្គនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ ខាងមុខនេះ។

កិច្ចប្រជុំដំណើរការតាមរបៀបវារៈដូចខាងក្រោម ៖

១. របាយការណ៍សកម្មភាពដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉ែត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
២. ការផ្តល់មតិយោបល់របស់ថ្នាក់ដឹកនាំ
៣. មតិសំណេះសំណាល បូកសរុបលទ្ធផល និងបិទកម្មវិធីដោយ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

២) របាយការណ៍សកម្មភាពដោយ ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉ែត អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

សេចក្តីរាយការណ៍ពីសកម្មភាព លទ្ធផលនានារបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែឧសភា ឆ្នាំ២០២៣។

នៅក្នុងបទបង្ហាញរបាយការណ៍ថ្នាក់ដឹកនាំ ជាពិសេសសកម្មភាពដ៏មមាញឹករបស់ ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តមអនុប្រធានប្រចាំការ ឯកឧត្តម លោកជំទាវអនុប្រធាន ក៏ដូចជាសកម្មភាព និងលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ សកម្មភាព និងព្រឹត្តិការណ៍សំខាន់ៗរួមមាន ៖

- បានធ្វើជាប្រធានកិច្ចប្រជុំគ្រប់គ្រង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែមេសា ឆ្នាំ២០២៣។
- បានធ្វើជាប្រធានកិច្ចប្រជុំជិតស្និទ្ធក្នុងចំណោមសមាជិកថ្នាក់ដឹកនាំ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានផ្តល់បទសម្ភាសន៍ ស្តីពីការឆ្លើយតបពហុវិស័យមេរោគអេដស៍ និងជំងឺអេដស៍ដល់ប្រទេសកម្ពុជា សុខភាព និងការអប់រំ សម្រាប់សហគមន៍។
- បានពិនិត្យ និងផ្តល់យោបល់លើឯកសារទាំងអស់ជូន ឯកឧត្តមទេសរដ្ឋមន្ត្រី សម្រាប់ការសម្រេចចិត្ត។
- បានពិនិត្យ និងចុះហត្ថលេខាលើសំណើរបេសកកម្ម។

- បានចូលរួមក្នុងការពិភាក្សាលើលទ្ធកម្ម។
- បានចូលរួមក្នុងកិច្ចប្រជុំ CCC លើកទី១០ និងទី១១។
- បានចូលរួមជាអធិបតីភាពក្នុងសិក្ខាសាលា ស្តីពីការអភិវឌ្ឍន៍ឃុំ សង្កាត់ និងផែនការវិនិយោគ នៅខេត្តតាកែវ។
- បានចូលួមជាប្រធានកិច្ចប្រជុំគណៈកម្មាធិការដឹកនាំ NASA VII។
- បានចូលរួមជាអធិបតីភាពក្នុងកិច្ចប្រជុំ ស្តីពីការរៀបចំសំណើ Core Group លើកទី៧ ក្នុងចំណោមសហគមន៍។
- បានចូលរួមក្នុងពិធីបុណ្យច្រត់ព្រះនង្គ័ល នៅខេត្តកំពង់ធំ។
- បានចូលរួមជាអធិបតីភាពក្នុងកិច្ចប្រជុំគណៈកម្មាធិការជំងឺអេដស៍។
- បានធ្វើជាតំណាងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជាមួយប្រតិភូ ក្រុមប្រឹក្សាកិបាល អាប (ABT)។
- បង្កើតទំនាក់ទំនងជាមួយសិល្បករ សិល្បការិនី តំណាងវិទ្យុABC និងតារាសម្តែង ដើម្បីរៀបចំការបណ្តុះបណ្តាល ស្តីពីការយល់ដឹងអំពីមេរោគអេដស៍ និងជំងឺអេដស៍។
- បានរៀបចំម៉ូឌុលបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ សម្រាប់គ្រូបង្គោលនៃក្រសួងអប់រំយុវជន និងកីឡា។
- ធ្វើជាវាគ្មិនអំពីមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

៣) ការផ្តល់មតិយោបល់របស់ថ្នាក់ដឹកនាំ

- **ឯកឧត្តមវេជ្ជបណ្ឌិត ជា ចាំ** បានលើកឡើងពីការទាក់ទងជាមួយតារាសិល្បៈដោយចាប់ផ្តើមពីពាក់កណ្តាលខែមិថុនា ឆ្នាំ២០២៣ អាចដំណើរការងារនេះបាន។
- ធ្វើកិច្ចការងារជាមួយតំណាងវិទ្យុ ABC ទាក់ទងនឹងការងារផ្សព្វផ្សាយអេដស៍តាមវិទ្យុ ABC។
- **ឯកឧត្តមវេជ្ជបណ្ឌិត ស៊ឹម គឹមសាន** បានលើកឡើងស្តីពី ៖

  ១) ត្រូវប្រកាសថាអេដស៍មិនទាន់ចប់នៅឡើយទេ សូមឱ្យប្រជាជនគិតពីអេដស៍ឡើងវិញ ជាពិសេសយុវវ័យពីអាយុ ១៦ឆ្នាំឡើយ។

  ២) សូមឱ្យប្រជាជនទាំងអស់ ជាពិសេសចាប់ផ្តើមពីមូលដ្ឋានជាមុន ត្រូវធ្វើតេស្តរកមេរោគអេដស៍ឱ្យបានគ្រប់ៗគ្នា។

៤) ការផ្តល់អនុសាសន៍ សូកសរុបលទ្ធផល និងចិទ្ធកម្មវិធីដោយ ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

- ការបកស្រាយស្ថិតក្នុងបទបង្ហាញគួរតែជាភាសាខ្មែរ។
- សេចក្តីព្រាងគោលនយោបាយជាតិមិនយកបង្ហាញនៅក្នុងកិច្ចប្រជុំពេញអង្គរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទេ។

- ការធ្វើបទបង្ហាញក្នុងកិច្ចប្រជុំពេញអង្គរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ គួរតែជាវឌ្ឍនភាព និងសមិទ្ធផលរយៈពេល៦ខែដំបូង ជាពិសេស IDpoor for PLHIV មូលនិធិសមធម៌ សម្រាប់ក្រុមគោលដៅមេរោគអេដស៍ ការចំណាយចំនួន ៦០លានរៀល និង៨០លានរៀល ផែនការមេរោគអេដស៍ និងជំងឺអេដស៍រួមបញ្ចូលក្នុងផែនការអភិវឌ្ឍន៍ និងវិនិយោគឃុំ។
- ខេត្ត Fast Track City ក្នុងខេត្តចំនួន០៤ ត្រូវត្រួតពិនិត្យជាបន្តបន្ទាប់។
- ការពិភាក្សាបន្ថែមជាមួយ NCHADS ដើម្បីធ្វើការសាកល្បង ដើម្បីទទួលបានមូលនិធិសន្តិសុខសង្គម។
- គោលនយោបាយជាតិ គឺលើកទឹកចិត្តអ្នកសង្ស័យឱ្យធ្វើតេស្ត និងកែលម្អការបង្ការ ផ្តោតលើការផ្សព្វផ្សាយស្រោមអនាម័យ ការដេករបាំងផ្លូវច្បាប់ និងការទំនាក់ទំនង ដើម្បីផ្លាស់ប្តូរអាកប្បកិរិយា។
- ទប់ស្កាត់ការឆ្លងមេរោគអេដស៍ត្រូវអនុវត្តតាមផែនទីបង្ហាញផ្លូវពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៥ លើការប្រើប្រាស់អន្តរាគមន៍បង្ការចំនួន ០៣ ដែលផ្តល់មូលនិធិដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MoEF)។
- បទអន្តរាគមន៍ពីវិធានការការពារត្រូវអនុវត្តដោយអង្គការសង្គមស៊ីវិល ដូច្នេះការគាំទ្រផ្នែកហិរញ្ញវត្ថុពីរាជរដ្ឋាភិបាលក៏ត្រូវបានផ្តួចផ្តើមផងដែរ។

ជាទីបញ្ចប់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានមានមតិសំណេះសំណាល បូកសរុបលទ្ធផលក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល និងប្រកាសបិទកម្មវិធីប្រជុំ។

អង្គប្រជុំត្រូវបានបញ្ចប់នៅវេលាម៉ោង ០៤:៣៥ នាទីល្ងាច នាថ្ងៃខែឆ្នាំដដែល។

ថ្ងៃសុក្រ ៦រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២៣

បានពិនិត្យត្រឹមត្រូវ អគ្គលេខាធិការ អ.ជ.ប.ជ.អ	អ្នកធ្វើកំណត់ហេតុ
	វេជ្ជ. ប៉ែន សេរីវង្ស
បានឃើញ និងឯកភាព ប្រធានអង្គប្រជុំ ទេសរដ្ឋមន្ត្រីប្រធាន អ.ជ.ប.ជ.អ	**បណ្ឌិត ឈឹម យិនដារ៉ែត**
អឿន-មូលី	